ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៥៧៤៧ មស.ក្រម

ថ្ងៃ ៧ ១៥កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៩

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ:**-ស្តីពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ ឋានន្តរស័ក្តិ ថ្នាក់កិត្តិយស និងដំឡើងឋានន្តរស័ក្តិ ថ្នាក់ តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល ។

**យោង:** -ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-លិខិតលេខ ៦០០ មស.នក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងថ្នាក់ ជូនមន្ត្រីរាជការស៊ីវិល

-ស្មារតីអង្គប្រជុំ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ស្តីពីនីតិវិធីក្នុងការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ ២០២០ និងការដំឡើងឋានន្តរស័ក្តិ ថ្នាក់ តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល នៅក្រសួងមុខងារសាធារណៈ ។

ខ្ញុំមានកិត្តិយស សូមគោរពជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នមេត្តាជ្រាបថា ដើម្បីឱ្យការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ ឋានន្តរស័ក្តិ ថ្នាក់កិត្តិយស និងដំឡើងឋានន្តរស័ក្តិ ថ្នាក់ តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល ឱ្យបានទាន់ពេលវេលា និងមានភាពងាយស្រួលបន្ថែមទៀតនោះ ក្រសួងមុខងារសាធារណៈ សូមធ្វើការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទមួយចំនួន លើការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ ឋានន្តរស័ក្តិ ថ្នាក់កិត្តិយស និងដំឡើងឋានន្តរស័ក្តិ ថ្នាក់តាមកម្រិតសញ្ញាបត្រ គ្រប់ក្របខ័ណ្ឌនៅក្រសួង ស្ថាប័ន មានដូចខាងក្រោម៖

**១-ការបង្កើតគណៈកម្មការចំណាត់ថ្នាក់**

ដោយអនុវត្តតាមខ្លឹមសារមាត្រា ២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា គ្រប់ក្រសួង ស្ថាប័ន ត្រូវជូនដំណឹងទៅដល់អង្គភាពក្រោមឱវាទ ឱ្យធ្វើការពិនិត្យវាយតម្លៃ និងដាក់ពិន្ទុពី ០ ដល់ ២០ ដល់បេក្ខជនដែលត្រូវស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់ក្នុងព្រឹត្តិបត្រពិន្ទុ តាមលក្ខណៈសម្បត្តិ ជាមូលដ្ឋានសម្រាប់ពិនិត្យដំឡើងឋានន្តរស័ក្តិ ថ្នាក់ ដូចមានចែងនៅក្នុងព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនានារបស់ក្របខ័ណ្ឌនីមួយៗ រួចធ្វើបញ្ជីរាយនាមបេក្ខជនទាំងនោះ ផ្ញើមកគណៈកម្មការចំណាត់ថ្នាក់របស់ក្រសួង ស្ថាប័ន ដើម្បីឱ្យគណៈកម្មការចំណាត់ថ្នាក់ របស់ក្រសួង ស្ថាប័ន ធ្វើការពិនិត្យ និងសម្រេច ។



ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតគណៈកម្មការចំណាត់ថ្នាក់ ដែលមានសមាសភាពដូចមានចែងក្នុងមាត្រា ២៥ ជំពូកទី ៤ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំធ្វើតារាងដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ(ដូចមានគំរូតារាងដំឡើងឋានន្តរស័ក្តិ ថ្នាក់ជូនភ្ជាប់មកជាមួយ) និងពិនិត្យពិភាក្សាវាយតម្លៃ សម្រេចក្នុងការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឱ្យបានត្រឹមត្រូវ ព្រមទាំងត្រូវបញ្ជូនសំណុំឯកសារមកដល់ក្រសួងមុខងារសាធារណៈ យ៉ាងយូរត្រឹមថ្ងៃទី **១៥** ខែ **មករា** រៀងរាល់ឆ្នាំ ។

ដោយឡែកចំពោះករណីមន្ត្រីរាជការ**ដែលដល់អាយុចូលនិវត្តន៍នៅឆ្នាំបន្ទាប់** (ការដំឡើងឋានន្តរស័ក្តិ ថ្នាក់កិត្តិយស) គ្រប់ក្រសួង ស្ថាប័ន ត្រូវលើកសំណើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់ ដូចមានចែងក្នុងមាត្រា ៣២ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា មកក្រសួងមុខងារសាធារណៈ **យ៉ាងតិចមួយឆ្នាំមុនពេលចូលនិវត្តន៍** ដើម្បីឱ្យក្រសួងមុខងារសាធារណៈ មានពេលវេលាគ្រប់គ្រាន់ក្នុងការផ្តល់ទិដ្ឋាការជូន និងធ្វើការបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ(បៀវត្ស) និងបោះពុម្ពសលាកប័ត្រចូលនិវត្តន៍ឱ្យស្របតាមឋានន្តរសក្តិ និងថ្នាក់ចុងក្រោយ ។

**២-បែបបទនៃការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ និងឋានន្តរស័ក្តិ ថ្នាក់កិត្តិយស (ឯកសារតម្រូវ)**

គ្រប់ក្រសួង ស្ថាប័នត្រូវបំពេញបែបបទក្នុងការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ និងការដំឡើងឋានន្តរស័ក្តិ ថ្នាក់កិត្តិយស ឯកសារពាក់ព័ន្ធរួមមាន៖

- -លិខិតស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់របស់ក្រសួង ស្ថាប័នសាមី ចំនួន ០១ច្បាប់
- -បញ្ជីរាយនាមមន្ត្រីរាជការស៊ីវិល ស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់(បេក្ខជន) តាមប្រភេទក្របខ័ណ្ឌ ចំនួន ០១ច្បាប់
- -កំណត់ហេតុស្តីពីការប្រជុំពិភាក្សា វាយតម្លៃរបស់គណៈកម្មការចំណាត់ថ្នាក់ ចំនួន ០១ច្បាប់
- -ប្រកាស អនុក្រឹត្យ និងព្រះរាជក្រឹត្យ ស្តីពីការដំឡើងឋានន្តរស័ក្តិ ថ្នាក់ចុងក្រោយ ចំនួន០ ១ច្បាប់

**៣-បែបបទនៃការដំឡើងឋានន្តរស័ក្តិ ថ្នាក់ តាមកម្រិតសញ្ញាបត្រ (ឯកសារតម្រូវ)**

សម្រាប់មន្ត្រីរាជការស៊ីវិលដែលស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់ តាមកម្រិតសញ្ញាបត្រ ត្រូវស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់ ដោយសំអាងលើសញ្ញាបត្រពិតប្រាកដ អនុវត្តអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងត្រូវធ្វើលិខិតមកក្រសួងមុខងារសាធារណៈ **តែមួយលើកប៉ុណ្ណោះគឺក្នុងខែសីហា រៀងរាល់ឆ្នាំ** ឯកសារពាក់ព័ន្ធរួមមាន៖

- -លិខិតស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់របស់ក្រសួង ស្ថាប័នសាមី ចំនួន ០១ច្បាប់
- -បញ្ជីរាយនាមមន្ត្រីរាជការស៊ីវិល ស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់(បេក្ខជន) តាមប្រភេទក្របខ័ណ្ឌ ចំនួន ០១ច្បាប់
- -ប្រកាស អនុក្រឹត្យ និងព្រះរាជក្រឹត្យ ស្តីពីការដំឡើងឋានន្តរស័ក្តិ ថ្នាក់ចុងក្រោយ ចំនួន០ ១ច្បាប់
- -ឯកសារពាក់ព័ន្ធផ្សេងៗតាមការចាំបាច់ ដូចជា សញ្ញាបត្រ វិញ្ញាបនបត្របញ្ជាក់ការសិក្សាថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ចំនួន ០១ច្បាប់

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នមេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

<u>**ចម្លងជូន**</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
" ដើម្បីជូនជ្រាប "
-ឯកសារ-កាលប្បវត្តិ

**ពេជ្រ ប៊ុនធិន**